**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ១៩៤៩ សជណ

ថ្ងៃ ព្រហ. ២រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២១

# ជម្រាបជូន

- **លោក លោកស្រីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ** ៖ ស្តីពីការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

**យោង** ៖- អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**លោក លោកស្រីប្រធានក្រុមប្រឹក្សា លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងលោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**ទាំងអស់ជ្រាបថា ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះមានចំនួន១១៥គោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានការិយាល័យច្រកចេញចូលតែមួយ។ ការិយាល័យនេះនឹងត្រូវបង្កើតនៅគ្រប់រដ្ឋបាលក្រុង និងស្រុក នៅក្នុងពេលឆាប់ៗខាងមុខនេះស្របតាមស្មារតីនៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧។

យោងតាមលទ្ធផលនៃការសិក្សាវាយតម្លៃរបស់ក្រុមសិក្សាឯករាជ្យអំពីស្ថានភាពបច្ចុប្បន្ននៃយន្តការបណ្តឹងតវ៉ានៅមូលដ្ឋាន បានបង្ហាញថាការិយាល័យប្រជាពលរដ្ឋបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល ជាពិសេសការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ។ ទន្ទឹមនេះ របាយការណ៍សិក្សាវាយតម្លៃក៏បានរកឃើញនូវចំណុចខ្វះខាតមួយចំនួនរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដែលត្រូវកែលម្អផងដែរ។

ផ្អែកលើបេកគំហើញនេះ ក្រសួងមហាផ្ទៃក៏បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌកាលដើមឆ្នាំ២០២១ ដើម្បីពិគ្រោះយោបល់ និងស្វែងរកអនុសាសន៍កែលម្អមួយចំនួនពាក់ព័ន្ធនឹងការពង្រឹងតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។ ឆ្លើយតបបញ្ហាប្រឈមដែលរកឃើញ និងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការបំពេញ



ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

តួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំមួយចំនួនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យនិងផ្តល់លទ្ធភាពគាំទ្រលើផែនការសកម្មភាពប្រចាំឆ្នាំ ដែលស្នើឡើងដោយប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។ អភិបាលក្រុង ស្រុក ខណ្ឌត្រូវដាក់បញ្ចូលផែនការសកម្មភាពទាំងនោះ ទៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមមាត្រា៥៤នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្តល់ព័ត៌មានត្រឡប់ឱ្យបានជាក់លាក់អំពីលទ្ធភាពនៃការគាំទ្រថវិកាទៅលើសកម្មភាពរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យប្រធានការិយាល័យបានដឹង និងងាយស្រួលក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន
- នៅពេលអនុម័តគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យមើល និងធានាថាផែនការសកម្មភាព និងថវិការបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកដែលមានសមត្ថភាពឱ្យទៅបំពេញការងារជាជំនួយការរបស់ប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ ស្របតាមការកំណត់ក្នុងមាត្រា៤៣ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវកំណត់តួនាទី ភារកិច្ចដល់បុគ្គលិកជំនួយការឱ្យបានច្បាស់លាស់ដើម្បីធានាប្រសិទ្ធភាពនៃការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវយកចិត្តទុកដាក់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី តួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋដល់អ្នកពាក់ព័ន្ធនិងប្រជាពលរដ្ឋ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់យន្តការនេះសម្រាប់សម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់លទ្ធភាពជូនការិយាល័យប្រជាពលរដ្ឋ ដើម្បីបញ្ជ្រាបការផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំ ឬវេទិកាសាធារណៈនានាដែលរៀបចំដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធានាឱ្យមានការការពារដល់ប្រធាន និងបុគ្គលិកការិយាល័យប្រជាពលរដ្ឋពីការគំរាមកំហែងនានា ក្នុងដំណើរការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ជាពិសេសនៅក្នុងដំណើរការស៊ើបអង្កេត និងសម្រុះសម្រួលដោះស្រាយបណ្តឹង

- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្តល់ប្រាក់បេសកកម្មដល់ប្រធានការិយាល័យប្រជាពលរដ្ឋ ក្រុង ស្រុក ខណ្ឌឱ្យស្មើនឹងប្រាក់បេសកកម្មរបស់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងត្រូវបែងចែកប្រាក់រង្វាន់លើកទឹកចិត្តដែលទទួលបានពីការផ្តល់សេវារដ្ឋបាលជូនប្រធាន និងបុគ្គលិកការិយាល័យប្រជាពលរដ្ឋ ដើម្បីឧបត្ថម្ភលើកទឹកចិត្តដល់យន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនេះ
- ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវជំរុញឱ្យអភិបាលក្រុង ស្រុក ខណ្ឌពិនិត្យលទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលការិយាល័យប្រជាពលរដ្ឋបានស្នើសុំអន្តរាគមន៍។ លើសពីនេះប្រធានក្រុមប្រឹក្សាត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

អាស្រ័យហេតុនេះ សូម**លោក លោកស្រីប្រធានក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងលោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ** ពិនិត្យ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **លោក លោកស្រី** ទទួលនូវការរាប់អានអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ កាលប្បវត្តិ